**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ:....០៤.....ស.ណ.ន.ចរ**

# សារលិខិតជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងឱកាសបុណ្យខួបកំណើតគម្រប់ ៦៦ឆ្នាំ ឈានចូល ៦៧ឆ្នាំ
## ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏នក្ខត្តឫក្សថ្លៃថ្លា ប្រកបដោយក្តីអភិរម្យសោមនស្សរីករាយនៃបុណ្យខួបកំណើត គម្រប់ជន្មាយុ ៦៦ឆ្នាំ ឈានចូល ៦៧ឆ្នាំ របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧នេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំ និងភរិយា សូមអភិវន្ទសម្តែងនូវសេចក្តីអំណរសាទរដោយស្មោះអស់ពីដួងចិត្ត និងសូមចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការ ចំពោះសម្តេច ប្រកបដោយសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅ និងកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ព្រមទាំងការកោតសរសើរក្រៃលែងចំពោះបញ្ញាញាណប្រកបដោយគតិបណ្ឌិតដ៏ផូរផង់ ទេពកោសល្យដ៏ឧត្តុង្គឧត្តមថ្លៃថ្លា និងសកម្មភាពស្នេហាជាតិ ប្រកបដោយគំរូវីរភាពដ៏ឆ្នើមល្បាញល្បី ពោរពេញដោយគុណធម៌និងមនុស្សធម៌ ក្នុងកិច្ចដឹកនាំនាវាកម្ពុជាជាទីស្នេហានៃយើងទាំងអស់គ្នា ទទួលបាននូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពនយោបាយ សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ដែលជាបុព្វបទដ៏សំខាន់សម្រាប់ការស្តារ និងការអភិវឌ្ឍមាតុភូមិ និងការកែទម្រង់រង្វើស៊ីជម្រៅលើគ្រប់វិស័យ ដែលមានអភិបាលកិច្ចជាស្នូលដ៏រឹងមាំ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់មនុស្សគ្រប់រូប។

តាំងពីអតីតកាល ក៏ដូចជាបច្ចុប្បន្នកាល សម្តេចតេជោនាយករដ្ឋមន្ត្រី នៅតែជាស្នូលដឹកនាំដ៏មោះមុតរឹងមាំខ្លាំងក្លាក្នុងការអនុវត្តគោលនយោបាយប្រកបដោយតម្លាភាព គុណធម៌ និងសច្ចធម៌ ដែលតម្កល់ផលប្រយោជន៍ជាតិជាចម្បង ហើយទទួលបាននូវការគាំទ្រ ជំនឿទុកចិត្ត និងទាក់ទាញបានសមានចិត្ត ការគោរពស្រឡាញ់ពីគ្រប់មជ្ឈដ្ឋានក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ជាងនេះទៀត តាមរយៈសមិទ្ធិផលដ៏ឧត្តុង្គឧត្តមឥតគណនា និងការដឹកនាំប្រកបដោយប្រសិទ្ធភាព សម្តេចតេជោនាយករដ្ឋមន្ត្រី គឺជាកុលបុត្រកម្ពុជាដ៏សែនឆ្នើម ជាមគ្គទ្ទេសក៍ដ៏ប៉ិនប្រសប់ និងជានិមិត្តរូបនៃសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍនៅកម្ពុជា។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏មង្គលាភិរម្យវិសេសវិសាលនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមអភិវន្ទលើកហត្ថបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បុណ្យបារមីដែលថែរក្សាប្រាង្គប្រាសាទអង្គរ ព្រះអង្គចេក ព្រះអង្គចម សូមព្រះអង្គតាមជួយថែរក្សាអភិបាលការពារប្រោះព្រំជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បុត្រា បុត្រី បុត្រប្រសារ និងចៅប្រុស

ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរដ៏ប្រសើរថ្លៃថ្លាបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងអភិវន្ទនកិច្ចដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងភរិយា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិសា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប៊ិន ឈិន**